**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:១៩៥ប្រ
ចុះថ្ងៃទី១៤ ខែមីថុនា ឆ្នាំ២០០៥
**សាលដីកា**
លេខ:០៧
ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៦

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅ:
១-ឯកឧត្តម ............ ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក ............... ជាចៅក្រមរបាយការណ៍
៤-លោក ................ ជាចៅក្រម
៥-លោក .................. ជាចៅក្រម

**ក្រឡាបញ្ជី**
-លោក ..................

**តំណាងមហាអយ្យការ**
-ឯកឧត្តម .............. ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ២៧"ឈ" ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៥០ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ ២០០៥ របស់សាលាឧទ្ធរណ៍រវាង

ដើមចោទឈ្មោះលគ (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥ឆ្នាំ មុខរបរ លក់ដូរ ទីលំនៅផ្ទះលេខ ១១Eo ផ្លូវលេខ១៤៦ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុង ភ្នំពេញ ។

មានមេធាវីលោក ឡគស។

ចុងចម្លើយឈ្មោះលជហ ភេទប្រុស អាយុ៨៥ឆ្នាំ ទីលំនៅផ្ទះលេខ ១៦Eo ផ្លូវលេខ ២៨២ សង្កាត់បឹងកេងកងទី ១ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

ចុងចម្លើយឈ្មោះលអមជ ភេទស្រី អាយុ៣៩ឆ្នាំ ទីលំនៅផ្ទះលេខ ១៥Eo ផ្លូវលេខ ៥៧ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

តតិយជនឈ្មោះជហល (ជាចុងបណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅផ្ទះលេខ ៣២Eo ផ្លូវលេខ១៦៨ សង្កាត់អូរឬស្សី២ ខណ្ឌ៧មករា ក្រុង ភ្នំពេញ ។

មានមេធាវីលោក អសវ ។

**កម្មវត្ថុបណ្តឹង:**ប្តឹងហាមឃាត់ការលក់ដូរ-ផ្ទេរសិទ្ធិ-បញ្ចាំឬជួល និងធ្វើអំណោយដល់អ្នកដទៃនូវដីក្នុងប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី

បានឃើញបណ្តឹងសាទុក្ខលេខ១១១ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៥ របស់លោក មេធាវីឡគសប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ២៧"ឈ" ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៩៥ប្រ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងសុំដីកាសម្រេចកិច្ចការប្រញាប់ចុះថ្ងៃទី០១-៤-២០០៤ ឈ្មោះលគ ប្តឹងសុំ ដូចមានក្នុងកម្មវត្ថុខាងលើដោយអាងហេតុថា : កាលពីថ្ងៃទី២៩-១០-១៩៩៣ ខ្លួនបានចុះកិច្ចសន្យាឱ្យប្រាក់ចំនួន ៧០.០០០ដុល្លា ទៅប្តីប្រពន្ធឈ្មោះលជហ និងលីម អ៊ុំមិជិញ ខ្ចីដោយអ្នកទាំងពីបានដាក់ដីទំហំ៤ហ-ត បញ្ចាំមកឲ្យខ្លួនដោយសន្យាថា សងប្រាកគ្រប់ចំនួនមកខ្លួនវិញ នៅថ្ងៃទី២៩-១០-១៩៩៤ តែរហូតមកដល់បច្ចុប្បន្ននេះ ទាំងពីនាក់ប្តីប្រពន្ធពុំបានសងប្រាក់ឱ្យខ្លួនវិញឡើយ ។

តាមបណ្តឹង(អង្គសេចក្តី) ចុះថ្ងៃទី ខែ៣ ឆ្នាំ២០០៤ របស់ឈ្មោះលគ ប្តឹងទាមទារ ប្រាក់ចំនួន ៧០.០០០ដុល្លាអាមេរិក ពីឈ្មោះលឹម ជីនហួរ និងប្រពន្ធឈ្មោះលីម អ៊ីមិជិញ ដោយមូលហេតុថា ខ្លួនបានធ្វើកិច្ចសន្យាចុះថ្ងៃទី២៩-១០-១៩៩៣ ឱ្យប្រាក់ចំនួន៧០.០០០ដុល្លាអាមេរិក ទៅប្តីប្រពន្ធនេះខ្ចី ដោយអ្នកទាំងពីរបានដាក់ដីទំហំ៤ហ.ត បញ្ចាំមកឱ្យខ្លួនដោយសន្យាសងប្រាក់ គ្រប់ចំនួនមកឱ្យខ្លួនវិញនៅថ្ងៃទី២៩-១០-១៩៩៤ តែរហូតមកដល់បច្ចុប្បន្នទាំងពីរនាក់ប្តីប្រពន្ធពុំបាន យកប្រាក់មកសងខ្លួនវិញឡើយ

បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខ១៥ប្រ*ច* ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៤ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងសុំដីកាសម្រេចកិច្ចការប្រញាប់របស់អ្នកស្រីលគ "ដើមចោទ" ចុះថ្ងៃទី០១-៤-២០០៤ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ហាមឃាត់មិនឱ្យឈ្មោះលជហ និងអ្នកស្រីលីម អ៊ីមិជិញ ធ្វើការលក់ដូរដូល បញ្ចាំ ផ្ទេរកម្មសិទ្ធិ ឬធ្វើអំណោយផ្សេងៗនូវប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ

០៨០ធ.VI4 ០៨១VI4 ចុះថ្ងៃទី២១-១០-១៩៩៣ និងប័ណ្ណលេខ១០៤ VI4 ១០៣ធVI4 ចុះថ្ងៃទី០៨-៣-១៩៩៤ ដែលមានដីស្ថិតនៅក្នុងភូមិព្រៃជីសាក់ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ទុកជាបណ្តោះអាសន្ន រង់ចាំតុលាការសម្រេចដល់អង្គសេចក្តី ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន៤.០០០៛ ។

៤-ដីកានេះបានជំនុំជំរះ និងសម្រេចចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ សម្រេចបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

៥-សេចក្តីសម្រេចនេះ មានអានុភាពអនុវត្តន៍ភ្លាមៗ ទោះបីមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ០២"ច" ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៥ របស់លោក អសវប្តឹងមិនសុខចិត្តនឹងដីកាសម្រេចកិច្ចការប្រញាប់លេខ១៥ប្រ"ច" ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៤ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ២៧"ឈ"ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៩-០១-២០០៥ របស់ឈ្មោះអសវមេធាវីរបស់ឈ្មោះជហល ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធដីកាសម្រេចកិច្ចកាប្រញាប់លេខ១៥ប្រ "ច" ចុះថ្ងៃទី០៨-០៤-២០០៤ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៣-ទទួលពាក្យបណ្តឹងសុំដីកាសម្រេចកិច្ចការប្រញាប់របស់អ្នកស្រីលគ ចុះថ្ងៃទី ០១-៤-២០០៤ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

៤-កាត់យកប្រាក់ប្រដាប់ក្តីដាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្តីនិង ពន្ធហ្នឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥០០០៛ និងអាជ្ញាធរតុលាការ៥០០០៛ ។

៥-សាលដីកានេះមានប្រសិទ្ធិភាពអនុវត្តភ្លាម ទោះជាមានបណ្តឹងសាទុក្ខក៏ដោយ

៦-សាលដីកានេះ ជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី០៤-០២-២០០៥ ចំពោះមុខ មេធាវីតំណាងឱ្យតតិយជនឈ្មោះដហល កំបាំងមុខឈ្មោះលគ មេធាវីឡាំង គឹមសេង, លឹម ជីនហួរ លីម អ៊ីមិជិញ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៥-១២-២០០៥ ចំពោះមុខ លោកមេធាវីតំណាងឱ្យឈ្មោះដហល ក៏បាំងមុខឈ្មោះលគលោកឡាំង គឹមសេង លជហ និងលីម អ៊ីមិជិញ ។

បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់

បានឃើញបណ្តឹងសាទុក្ខលេខ១១១ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៥ របស់លោកមេធាវីឡគសប្តឹងមិនសុខចិត្តនិងសាលដីការដ្ឋប្បវេណីលេខ២៧"ឈ" ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៥ របស់ឈ្មោះលគ ។

បានឃើញសារណាតបចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៥ របស់ឈ្មោះដហល ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា:សាលាឧទ្ធរណ៍សម្រេចសេចក្តីមកនេះត្រឹមត្រូវហើយ ។ សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ ។

បានស្តាប់ក្រឡាបញ្ជីអានសារណារបស់អ្នកស្រីលគ ។

បានស្តាប់ក្រឡាបញ្ជីអានសារណារបស់លោកដហល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកឡគសជាមេធាវីការពារឱ្យដើមចោទ បានលើកឡើងថា : ការលើកឡើងក្នុងសារណារបស់គូភាគីមានសំអាងរៀងៗខ្លួន ។ រឿងនេះមិនមែន កូនក្តីខ្លួនសុំដើម្បីយកមកលក់ទេ គ្រាន់តែហាមឃាត់ទុកប៉ុណ្ណោះ ដើម្បីកុំឱ្យប៉ះពាល់ដល់ផល ប្រយោជន៍របស់គូភាគី ព្រោះសំណុំរឿងកំពុងតែចាត់ការនៅតុលាការក្រុងភ្នំពេញ ។

**សំណូមពរ** សូមឯកឧត្តមប្រធាននឹងក្រុមប្រឹក្សាជំនុំជំរះសម្រេចបដិសេធសាលដីការបស់ សាលាឧទ្ធរណ៍ និងតម្កល់ដីកាសម្រេចកិច្ចការប្រញាប់របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកអសវជាមេធាវីការពារឱ្យតតិយជន បានលើកឡើងថា ក្រុមហ៊ុន TATUNG នៅក្រៅស្រុក ក្រុមហ៊ុន LANSONG នៅស្រុកខ្មែរ ក្រុមហ៊ុនទាំងពីរបានធ្វើក្រុមហ៊ុនជាមួយគ្នា ។ លោកលជហ ឈរឈ្មោះនៅស្រុកខ្មែរ លោកឈិន ហុង ឈរឈ្មោះនៅក្រៅស្រុក ។ លោកលជហ ក្រោយពីបានទទួលលុយដែលផ្ទេរមកពីបរទេសបានគេចខ្លួនបាត់ ។ក្រោយមកក្រុមហ៊ុនTATUNG បានទំនាក់ទំនងជាមួយក្រុមហ៊ុន POPULAR ដើម្បីទារបំណុលពីលោកលជហ ដោយលោកស្រីអេន នី បានប្រគល់សិទ្ធិឱ្យ ទៅលោកជា ហេងលើ ។

**សំណូមពរ** សុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់ដើមចោទ សារណារបស់តតិយជនលោកជហល និងសេចក្តីសន្និដ្ឋានរបស់មេធាវី នៃគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ១១១ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៥ រស់ លោកឡុគសការពារដើមចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿង នេះមកជំនុំជំរះបាន ដោយយោងតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់ សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចបដិសេធដីកាកិច្ចការប្រញាប់លេខ១៥ប្រ"ច" ចុះថ្ងៃទី០៨-០៤-២០០៨ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ និងបដិសេធបណ្តឹង សុំកិច្ចការប្រញាប់ចុះថ្ងៃទី០១-០៤-២០០៤ របស់អ្នកស្រីលគ ដោយអាងហេតុថា សាលក្រមលេខ ១៩"ប" ចុះថ្ងៃទី០៤-៦-២០០២ របស់តុលាការក្រុងភ្នំពេញចូលជាស្ថាពរហើយនោះ ជាការពុំទាន់ត្រឹមត្រូវទេ ពីព្រោះថា បណ្តឹងសុំរបស់អ្នកស្រីលី គង គ្រាន់តែជាវិធានការបណ្តោះអាសន្នប៉ុណ្ណោះ ហើយការផ្ទេរកម្មសិទ្ធិដីទាំង៤ប្លង់ ជាកម្មវត្ថុបណ្តឹងហាមឃាត់មានលក្ខណៈអនិយតៈភាព លើច្រើនចំណុចដែលគប្បីទុកឱ្យតុលាការអង្គសេចក្តីពិនិត្យ និងសម្រេចដោយមានការជានា ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍អនុញ្ញាតឱ្យអនុវត្តសាលដីការបស់ខ្លួនភ្លាមៗ នោះជាការបំពានទៅនឹងមាត្រា២១៧ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលអាចអនុវត្តក្នុងរឿង រដ្ឋប្បវេណីផងដែរ ។

- យល់ឃើញថា ក្នុងរឿងនេះ គូភាគីពុំបានចូលខ្លួនមកនាពេលសវនាការនេះទេ ប៉ុន្តែមេធាវីរបស់គូភាគីបានចូលរួមហើយ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណ៍លេខ២៧"ឈ" ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## ទនិច្ឆ័យសេចក្តីកំបាំងមុខគូក្តី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ១១១ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៥ របស់លោកមេធាវី ការពារឱ្យដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធសាលដីការដ្ឋប្បវេណីលេខ ២៧"ឈ" ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ចោលជាអសារបង់ដោយឥតបង្វិល ។

៣-សម្រេចហាមឃាត់ឈ្មោះលឹម ជិនហួរ និងអ្នកស្រីលអមជ មិនឱ្យធ្វើការលក់ដូរ ជួល ផ្ទេរកម្មសិទ្ធិ ឬធ្វើអំណោយផ្សេងៗនូវប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ០៨០ធV14,០៨១ធV14 ចុះថ្ងៃទី២១-១១-១៩៩៣ និងប័ណ្ណលេខ១០៤ធV14, ១០៣ធ V14 ចុះថ្ងៃទី៨-០៣-១៩៩៤ ដែលមានដីស្ថិតនៅក្នុងភូមិព្រៃជីសាក់ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ជាបណ្តោះអាសន្ន រង់ចាំតុលាការសម្រេចដល់អង្គសេចក្តី ។

៤-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ១៩៥ប្រ ចុះថ្ងៃទី១៤-០៦-២០០៥ របស់តុលាការកំពូល ទៅតុលាការក្រុងភ្នំពេញ ដើម្បីបញ្ចូលក្នុងរឿងនៃអង្គសេចក្តី ។

៥-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩០០០៛ ដែលចុងចម្លើយបានបង់គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សម្រាប់ជា រង្វាន់ត្រឡាបញ្ជីកាន់ហើបប្រាក់.

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ។

៦-សាលដីកានេះ ប្រកាសនោះសវនាការជាសាធារណៈនៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៦។